# ព្រឹត្តបត្រព័ត៌មាន

# អំពីស្ត្រី



ជំរុញសមភាពយេនឌ័រក្នុងសង្គមមួយ ដែលស្ត្រីអាចប្រើប្រាស់សិទ្ធិរបស់ខ្លួនមានតុល្យភាព និងអាចកសាងសមត្ថភាពដើម្បីក្លាយជាអ្នកមានភាពម្ចាស់ការ

http://women.open.org.kh

ឆ្នាំទី ៖ ០១ លេខ ៖ ០០៤ ចេញផ្សាយសម្រាប់ខែសីហា-កញ្ញា ឆ្នាំ២០១០


## បទវិចារណកថា

### គុណតម្លៃរបស់ស្ត្រីក្នុងការចូលរួមលើវិស័យធុរកិច្ចសង្គម

បើយើងពិនិត្យមើលលើស្ថានភាពជាក់ស្តែងនៅក្នុងសង្គមកម្ពុជា យើងសង្កេតឃើញថា ស្ត្រីកាន់តែច្រើនឡើងបានប្រកបមុខរបរ ឬក៏ថាចូលរួមក្នុងវិស័យធុរកិច្ចស្ទើរតែគ្រប់ផ្នែក។

ការចូលរួមរបស់ស្ត្រីជាទូទៅក្នុងវិស័យធុរកិច្ចគឺពិតជាមានតម្លៃដ៏ធំធេង និងមិនអាចកាត់ថ្លៃបានឡើយ។ ពាក្យមួយឃ្លាដែលពោលថា"ស្ត្រីគឺជាឆ្អឹងខ្នងនៃសេដ្ឋកិច្ចជាតិ" គឺពិតមានន័យទូលំទូលាយ ហើយយើងពិតជាកោតសរសើរដល់អ្នកផ្តួចផ្តើមគំនិតបង្កើតពាក្យមួយឃ្លានេះ។

បើទោះជានៅក្នុងកាលៈទេសៈដ៏លំបាកលំបិនប្រកបដោយឧបសគ្គបែបណាក៏ដោយ ក៏ស្ត្រីខ្មែរតែងតែបានតស៊ូយ៉ាងស្វិតស្វាញអំណត់អត់ធន់នៅក្នុងមុខរបរទាំងនេះ។ ពួកគេពិតជាបាននិងកំពុងចូលរួមយ៉ាងសកម្មក្នុងធុរកិច្ចផ្សេងៗ ក៏ដូចជាកិច្ចការអភិវឌ្ឍន៍សេដ្ឋកិច្ច

(តទៅទំព័រទី ២)

## មាតិកា


- អនុសញ្ញាស្តីពីការបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនារីភេទ ទំព័រទី៣
- ស្ត្រីកម្ពុជាក្នុងអាជីវកម្ម ទំព័រទី៥
- វិធីសាស្ត្រ គ្រប់គ្រងមុខជំនួញធុនតូចឲ្យបានជោគជ័យ ទំព័រទី៧
- ការណែនាំអំពីកម្មវិធីការិយាល័យភាសាខ្មែរ ទំព័រទី៧


## សង្គម និងការអភិវឌ្ឍន៍




ការពិភាក្សាក្នុងសិក្ខាសាលាស្តីអំពី " ស្ត្រី កម្ពុជា ក្នុង អាជីវកម្ម "
រូបភាព៖ គេហទំព័រ ហ្វេសប៊ុក ស្ត្រីកម្ពុជាក្នុងអាជីវកម្ម

### កាលានុវត្តនភាព របស់ ស្ត្រី ក្នុង វិស័យ សេដ្ឋកិច្ច

ថ្វីបើស្ត្រីមានចំនួនច្រើននៅក្នុងសង្គមក្តី ក៏កាលានុវត្តភាពស្ត្រីក្នុងសេដ្ឋកិច្ច នៅមានកម្រិតនៅឡើយ។ លទ្ធផលជំរឿនក្នុងបណ្តាឆ្នាំកន្លងមកបានបង្ហាញថា ប្រជាពលរដ្ឋខ្មែរជាង ៥០% គឺជាស្ត្រី ។ តួលេខនេះ បាន ស ឲ្យឃើញថាស្ត្រី ជាធនធាន ពលកម្មមួយ ដ៏សំខាន់សម្រាប់អភិវឌ្ឍសេដ្ឋកិច្ចជាតិ។

តែជាក់ស្តែង អត្រាចូលរួមសកម្មភាព

(តទៅទំព័រទី ៦)

## ទេពកោសល្យស្ត្រី និងបុរស

### ពាក្យថា ស្ត្រីបង្វិលចង្ក្រានមិនជុំ មិនអាចយកមកអនុវត្តសម្រាប់ស្ត្រីនៅសម័យបច្ចុប្បន្នបានទេ

បន្ទាប់ពីបានបញ្ចប់ថ្នាក់ ឧត្តមសិក្សាកម្រិតបរិញ្ញាបត្រផ្នែកគណនេយ្យ ពីវិទ្យាស្ថានជាតិ គ្រប់គ្រង និងផ្នែកភាសាអង់គ្លេស ពីវិទ្យាស្ថាន ភាសាបរទេស កាលពីឆ្នាំ២០០៤ រួចមក លោកស្រី ហេង ចិន្តា បានក្លាយជាស្ត្រីខ្មែរមួយរូបដែលប្រកបដោយ ទេពកោសល្យខ្ពស់ខាងផ្នែកមុខជំនួញ។ អ្វីដែលស្តែងឲ្យឃើញនូវទេពកោសល្យដ៏ប៉ិនប្រសព្វរបស់ លោកស្រី ហេង ចិន្តា គឺ ការបង្កើតនូវសិប្បកម្ម កែច្នៃកន្ទេល និងសូត្រខ្មែរ ឲ្យក្លាយជាវត្ថុអនុស្សាវរីយ៍ប្រណីតៗ សម្រាប់នាំចេញទៅលក់នៅបរទេសប្រកបដោយជោគជ័យ។ ក្រៅពីនោះ លោកស្រីថែមទាំងធ្វើជាទីប្រឹក្សាក្នុងមុខជំនួញរបស់ស្វាមី

(តទៅទំព័រទី ៤)

## បទវិចារណកថា

( តពីទំព័រទី ១ )

និងការងារសង្គមផងដែរ។

យើងពិតជាដឹងហើយថា សង្គមកម្ពុជាមានចំនួនស្ត្រីច្រើនជាងបុរស ហើយបើតាមតួលេខរបស់គម្រោងបញ្ជ្រាបយេនឌ័រ និងការបង្កើតគោលនយោបាយតាមរយៈការពង្រឹងសមត្ថភាពផ្នែកព័ត៌មាន និងស្រាវជ្រាវ (PGM) របស់ក្រសួងកិច្ចការនារីក្នុងឆ្នាំ២០០៧ ក៏បានបង្ហាញដែរថា ការលក់ដុំនិងលក់រាយ ការងារផលិត ការងារកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គឺស្ត្រីមានចំនួនច្រើនជាងបុរស។ ទាំងនេះសុទ្ធតែជាគុណតម្លៃដ៏ធំធេងរបស់ស្ត្រីក្នុងការងារធុរកិច្ច។ នេះគឺអាចបញ្ជាក់បានថា ស្ត្រីគឺពិតជាកម្លាំងស្នូលនៃការកសាង និងអភិវឌ្ឍន៍សេដ្ឋកិច្ចទាំងនៅក្នុងសង្គមគ្រួសារ និងនៅសង្គមជាតិទាំងមូល។

ប៉ុន្តែទោះបីជាយ៉ាងនេះក្តី ក៏គុណតម្លៃទាំងនេះនៅតែត្រូវបានគេមើលរំលងនៅក្នុងសង្គមកម្ពុជា។ រាល់កិច្ចការទាំងពួង បើទោះជាស្ត្រីជាអ្នករាប់រងចេញមុខក៏ដោយ ក៏ស្ត្រីជាភរិយា និងជាមេផ្ទះត្រូវតែមានការយល់ព្រមពីបុរសជាស្វាមី ឬក៏ជាមេគ្រួសារ។ ការដែលមិនអាចធ្វើសេចក្តីសម្រេចចិត្តដោយខ្លួនឯងបានបែបនេះ ក៏ដោយសារតែនៅមានឧបសគ្គពីរធំៗ។

ឧបសគ្គទីមួយគឺកម្ពុជានៅមិនទាន់ជម្រះចោលនូវផ្នត់គំនិតដែលថា ស្ត្រីវិលចង្ក្រានមិនជុំ មុជមិនជ្រៅទៅមិនឆ្ងាយ ដែលចាំបាច់ត្រូវតែពឹងពាក់លើការសម្រេចចិត្តពីបុរសជាមេគ្រួសារ។ ផ្នត់គំនិតចាស់គំរិលនេះជាប់ទាក់ទិននឹងវប្បធម៌ប្រពៃណី ដោយបានចាត់ទុកស្ត្រីថា ជាមនុស្សមានកម្លាំងទន់ខ្សោយ មានប្រាជ្ញាស្មារតីមិនរឹងប៉ឹងដូចបុរស ដោយមិនអាចសម្រេចកិច្ចការធំៗបានដូចបុរសឡើយនៅក្នុងសង្គមជាតិ។

ឧបសគ្គទីពីរគឺស្ត្រីខ្លួនឯងនៅមិនទាន់មានសេចក្តីក្លាហានគ្រប់គ្រាន់ក្នុងការធ្វើសេចក្តីសម្រេចចិត្តនានា។ នៅត្រង់ចំណុចនេះ វាអាចបណ្តាលមកពីការចាប់ផ្តើមដំបូងរបស់ពួកគេតាំងពីកុមារភាពមក គឺថា កុមារីបានទទួលការរៀនសូត្រនិងចំណេះដឹងទូទៅទាបជាងកុមារា ហើយការបន្តចូលរៀនរបស់យុវតីនៅតាមវិទ្យាល័យ និងសាកលវិទ្យាល័យក៏នៅមានចំនួនទាបជាងបុរសវ័យជំទង់ដែរ បើទោះជាកុមារី និងយុវតីមានសក្តានុពលក្នុងការទទួលយកការអប់រំជាន់ខ្ពស់ និងអាចមានលទ្ធភាពក្នុងការស្តារនិងអភិវឌ្ឍន៍សង្គមគ្រួសារ និងសង្គមជាតិយ៉ាងណាក៏ដោយ។

ដោយមើលឃើញពីគុណតម្លៃរបស់ស្ត្រីក្នុងការបំពេញធុរកិច្ចនានានៅក្នុងសង្គម និងឧបសគ្គផ្សេងៗដែលនាំឲ្យមានការបន្ទាបនូវគុណតម្លៃនេះ យើងទាំងអស់គ្នាត្រូវតែជំរុញ និងលើកស្ទួយ ហើយស្វែងរកដំណោះស្រាយចំពោះឧបសគ្គទាំងនោះ ដើម្បីឲ្យស្ត្រីក្លាយជាកម្លាំងស្នូលពិតប្រាកដក្នុងការទ្រទ្រង់សេដ្ឋកិច្ចជាតិ។

ជាងនេះទៅទៀត ដើម្បីរក្សា និងលើកស្ទួយគុណតម្លៃដែលជាស្នាដៃ និងជាទេពកោសល្យដ៏ប៉ិនប្រសប់របស់ស្ត្រីខ្មែរឲ្យនៅស្ថិតស្ថេរ សង្គមទាំងមូលត្រូវផ្តល់ការលើកទឹកចិត្ត និងជួយបង្កើនសមត្ថភាពដល់កុមារី និងស្ត្រី ដោយផ្តល់ឲ្យពួកគេនូវការការពារ ផ្តល់ការលើកទឹកចិត្ត ជំរុញនិងលើកទឹកចិត្ត ផ្តល់ការអប់រំ បណ្តុះបណ្តាល ផ្តល់ប្រឹក្សាយោបល់ ចែកជូនបទពិសោធន៍ ចំណេះដឹង មេរៀនទទួលបាន និងការអនុវត្តល្អៗ ផ្តល់ឧកាស និងសិទ្ធិការធ្វើសេចក្តីសម្រេចចិត្តនៅគ្រប់កម្រិតក្នុងគ្រប់វិស័យ។ សង្គមទាំងមូលត្រូវតែលុបបំបាត់រាល់ការរើសអើង ការមាក់ងាយ និងការប្រព្រឹត្តអំពើហិង្សាលើស្ត្រី ប៉ុន្តែត្រូវធ្វើឲ្យប្រសើរឡើងនូវស្ថានភាពសុខភាព បង្កើនការចូលរួមនៅក្នុងវិស័យអប់រំ និងការលើកកម្ពស់សមត្ថភាពរបស់ពួកគេបន្ថែមទៀត។

រួមគ្នាលើកកម្ពស់គុណតម្លៃរបស់ស្ត្រីក្នុងការចូលរួមក្នុងវិស័យធុរកិច្ច ដើម្បីសង្គមរីកចម្រើន៕

សម្រាប់ឯកសារនេះជាអេឡិចត្រូនិកៈ http://women.open.org.kh/km/editerial-women-in-business


## ក្រុមការងារកម្មវិធីស្ត្រី

**លោកស្រី ជឹម ម៉ាណាវី**
និពន្ធនាយក និងជានាយិកាប្រតិបត្តិ

**លោក ឆាយ សុផល**
អ្នកនិពន្ធ

**កញ្ញា កៅ ពៅលក្ខិណា**
ជំនួយការអ្នកគ្រប់គ្រងកម្មវិធីស្ត្រី

**អាន សុប៉ូលី**
អ្នករចនាទំព័រ និង និពន្ធ

**លោក អេង វណ្ណៈ**
អ្នកគ្រប់គ្រងតំបន់បណ្តាញ

**លោកស្រី ប្រាក់ សុខាយុ**
អ្នកជំនួយការគម្រោង

**លោក ម៉ក់ តារា**
ជំនួយការបច្ចេកទេសទូទៅ

**កញ្ញា សូ ចាន់នីម**
អ្នកវាយអត្ថបទ


កម្មវិធីស្ត្រីនៃអង្គការវិទ្យាស្ថានបើកទូលាយ សូមថ្លែងអំណរគុណចំពោះមិត្តអ្នកអាន ដែលបានគាំទ្រប្រើប្រាស់វិបផតថលស្តីអំពីស្ត្រី និងព្រឹត្តិបត្រព័ត៌មានអំពីស្ត្រី។ ក្រុមការងារយើងខ្ញុំ សូមស្វាគមន៍នូវរាល់មតិយោបល់ ការរិះគន់ក្នុងន័យស្ថាបនា និងការផ្តល់ជាអត្ថបទ ឬបទសម្ភាសន៍របស់មិត្តអ្នកអាន ដែលមានខ្លឹមសារសមស្របទៅនឹងគោលបំណងរបស់កម្មវិធីស្ត្រី ដើម្បីចុះផ្សាយលើវិបផតថលស្តីអំពីស្ត្រី និងព្រឹត្តិបត្រព័ត៌មានអំពីស្ត្រី ។


ក្រសួងព័ត៌មាន
MINISTRY OF INFORMATION
លេខ ៤៨៥ ព.ម.ឋក

ព្រឹត្តិប័ត្រព័ត៌មានអំពីស្ត្រី ទទួលបានច្បាប់អនុញ្ញាតិចេញផ្សាយពីក្រសួងព័ត៌មាន តាមលិខិតលេខ ៤៨៥ ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ២០០៩។

## ច្បាប់ និងសិទ្ធិ

# អនុសញ្ញាស្តីពីការបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ

(តពីលេខមុន)

### មាត្រា ៤

១. ការអនុម័តដោយរដ្ឋភាគី នូវវិធានការពិសេសបណ្តោះអាសន្ន ដើម្បីពន្លឿនការកសាងសមភាពរវាងបុរសនិងស្ត្រី មិនត្រូវចាត់ទុកជាការរើសអើងដូចបានចែងក្នុងអនុសញ្ញានេះទេ ប៉ុន្តែទោះតាមបែបណាមួយក៏ដោយ មិនត្រូវមានន័យថា រក្សាទុកបទដ្ឋានវិសមភាព ឬដាច់ដោយឡែកឡើយ វិធានការទាំងនេះត្រូវដាក់ឱ្យនិរាករណ៍ នៅពេលគោលដៅខាងសមភាពនៃឱកាស និងនៃការប្រព្រឹត្តមកលើស្ត្រីបានសម្រេចហើយ។

២. ការអនុម័តដោយរដ្ឋភាគីនូវវិធានការពិសេស រួមមានវិធានការទាំងឡាយដែលមានក្នុង អនុសញ្ញានេះផង ដើម្បីការពារមាតុភាព មិនត្រូវចាត់ទុកជាការរើសអើងឡើយ។

### មាត្រា ៥

រដ្ឋភាគី ត្រូវប្រកាន់យកវិធានការសមស្របទាំងអស់ ដើម្បី៖

(ក) កែប្រែផ្នត់គំនិតឥរិយាបថសង្គម និងវប្បធម៌របស់បុរសនិងស្ត្រី ដើម្បីសម្រេចបាននូវការលុបបំបាត់ចោលសេចក្តីលំអៀង និងទម្លាប់ និងការអនុវត្តជាទម្លាប់ផ្សេងៗទៀត ផ្អែកលើគំនិតស្តីពីភាពទាបជាង ឬខ្ពស់ជាងរបស់ភេទណាមួយ ឬលើតួនាទីជាទម្លាប់សម្រាប់បុរសនិងស្ត្រី។

(ខ) ធានាថា ការអប់រំគ្រួសារ មានរាប់បញ្ចូលការយល់ដឹងត្រឹមត្រូវអំពីមាតុភាព ដែលជាមុខងាររបស់សង្គម និងការទទួលស្គាល់ ការទទួលខុសត្រូវរួមរបស់បុរសនិងស្ត្រី ក្នុងការចិញ្ចឹមកូន និងការអភិវឌ្ឍន៍របស់កូន ហើយប្រការនេះក៏ត្រូវមានការយល់ថា ប្រយោជន៍របស់កុមារគឺជាលក្ខខណ្ឌចម្បងក្នុងគ្រប់ករណីទាំងអស់។



ទិដ្ឋភាពកិច្ចប្រជុំសមាជិកគណៈកម្មការនៃអង្គការមិនមែនរដ្ឋាភិបាលកម្ពុជា
ដើម្បីអនុសញ្ញាលុបបំបាត់រាល់ទម្រង់នៃការរើសអើងលើស្ត្រីភេទ (NGO-CEDAW)
រូបភាពដោយ៖ អង្គការវិទ្យាស្ថានបើកទូលាយ

### មាត្រា ៦

រដ្ឋភាគី ត្រូវប្រកាន់យកវិធានការសមស្របទាំងអស់ រួមមានការធ្វើច្បាប់ផង ដើម្បីបង្ក្រាបគ្រប់ទម្រង់នៃការជួញដូរស្ត្រី និងអាជីវកម្មពេស្យាកម្មលើស្ត្រី។

### ផ្នែកទី ២

### មាត្រា ៧

រដ្ឋភាគី ត្រូវប្រកាន់យកវិធានការសមស្រប ដើម្បីលុបបំបាត់ចោលការរើសអើងប្រឆាំងនឹងស្ត្រី ក្នុងជីវភាពនយោបាយ និងសាធារណៈរបស់ប្រទេស និងជាពិសេសត្រូវធានាដល់ស្ត្រីនូវលក្ខខណ្ឌស្មើភាពជាមួយបុរសនូវ សិទ្ធិ ៖

(ក) បោះឆ្នោតនៅគ្រប់ការបោះឆ្នោត និងការធ្វើប្រជាមតិសាធារណៈ និងមានសិទ្ធិឈរឈ្មោះបោះឆ្នោតសម្រាប់អង្គការសាធារណៈដែលជ្រើសរើសដោយបោះឆ្នោត។

(ខ) ចូលរួមតាក់តែងគោលនយោបាយរបស់រដ្ឋ និងការអនុវត្តគោលនយោបាយ កាន់មុខការ សាធារណៈ និងបំពេញមុខងារសាធារណៈ នៅគ្រប់កម្រិតជាន់ថ្នាក់របស់រដ្ឋាភិបាល។

(គ) ចូលរួមក្នុងអង្គការ និងសមាគមក្រៅរដ្ឋាភិបាល ដែលពាក់ព័ន្ធនឹងជីវភាពសាធារណៈ និង នយោបាយរបស់ប្រទេសជាតិ។

### មាត្រា ៨

រដ្ឋភាគី ត្រូវប្រកាន់យកវិធានការសមស្របទាំងអស់ ដើម្បីធានាឱ្យស្ត្រីមានឱកាសធ្វើជាតំណាងរដ្ឋាភិបាលនៅថ្នាក់ អន្តរជាតិ និងចូលរួមក្នុងកិច្ចការរបស់អង្គការអន្តរជាតិ ដោយផ្អែកលើលក្ខខណ្ឌស្មើភាពជាមួយបុរស និងដោយគ្មានការរើសអើង។

### មាត្រា ៩

១. រដ្ឋភាគី ត្រូវផ្តល់ឱ្យស្ត្រីនូវសិទ្ធិស្មើគ្នានឹងបុរសក្នុងការទទួល ផ្លាស់ប្តូរ ឬរក្សាទុកសញ្ជាតិរបស់ខ្លួន។ រដ្ឋភាគីត្រូវធានាជាពិសេសថា ការរៀបអាពាហ៍ពិពាហ៍ជាមួយជនបរទេស ឬការផ្លាស់ប្តូរសញ្ជាតិរបស់ប្តីក្នុងពេលអាពាហ៍ពិពាហ៍ មិនធ្វើឱ្យផ្លាស់ប្តូរជាស្វ័យប្រវត្តិនូវសញ្ជាតិរបស់ប្រពន្ធ មិនធ្វើឱ្យប្រពន្ធគ្មានសញ្ជាតិ ឬបង្ខំឱ្យប្រពន្ធយកសញ្ជាតិរបស់ប្តីឡើយ។

២. រដ្ឋភាគី ត្រូវផ្តល់ឱ្យស្ត្រីនូវសិទ្ធិស្មើគ្នានឹងបុរសក្នុងការសម្រេចពីសញ្ជាតិរបស់កូនផងដែរ។

(មានតទៅលេខក្រោយ)

សម្រាប់ឯកសារនេះជាអេឡិចត្រូនិក៖
http://women.open.org.kh/km/cedaw_kh

## ឱកាសសេដ្ឋកិច្ចសម្រាប់ស្ត្រី និងបុរស

(តពីទំព័រទី ១)

ដែលជាម្ចាស់ក្រុមហ៊ុនមួយដ៏ធំនៅកម្ពុជា ឈ្មោះ "ខេអិនអិន ខេមបូឌា ខូអិល ធី ឌី លីមីធីត"ដែលជាក្រុម ហ៊ុននាំចូលគ្រឿងបន្លាស់រថយន្ត គ្រឿងចក្រ សំណង់ សំលៀកបំពាក់ជជុះ និង បម្រើសេវាកម្ម អចលនទ្រព្យ។

ដោយសង្កេតឃើញអំពីសក្តានុពលខ្ពស់នៃកន្ទេលខ្មែរ រួមផ្សំ នឹងសូត្រខ្មែរ ដែលពុំទាន់ត្រូវបានគេយកមកកែច្នៃនៅឡើយ និងដោយចង់បង្កើតការងារសម្រាប់ជនពិការក៏ដូចជាស្ត្រីខ្មែរក្នុងស្រុក លោកស្រី ហេង ចិន្តា ក៏ផុសចេញនូវគំនិតមួយដែលចង់យកវត្ថុសាមញ្ញទាំងពីរប្រភេទនេះមកផ្គុំបញ្ចូលគ្នា ឲ្យកើតចេញជាវត្ថុអនុស្សាវរីយ៍ ដ៏ប្រណីត ហើយដែលអាចទាក់ទាញភ្ញៀវអតិថិជនទាំងក្នុង និងក្រៅស្រុក។ ការផុសចេញនូវគំនិតមួយនេះអនុញ្ញាតឲ្យលោកស្រី បង្កើត ឡើងជារូបរាងក្នុងឆ្នាំ២00៤ នូវសិប្បកម្មខ្មែរមួយឈ្មោះថា "សិប្បកម្ម ខ្មែរ ខេ អិន អិន" ឬ ជាភាសា អង់ គ្លេស ថា "KNN Cambodia Arts and Crafts" ដែល ជាផ្នែកមួយនៃក្រុមហ៊ុន ខេ អិន អិន ខេមបូឌា ។



ទិដ្ឋភាព ហាងលក់ សិប្បកម្ម ខ្មែរ ខេ អិន អិន
រូបភាពដោយៈ សិប្បកម្ម ខ្មែរ ខេ អិន អិន



បុគ្គលិកសិប្បកម្ម ខ្មែរ ខេ អិន អិន
រូបភាពដោយៈ សិប្បកម្ម ខ្មែរ ខេ អិន អិន

លោកស្រី បានមានប្រសាសន៍ប្រាប់ក្នុងបទសម្ភាសន៍ថាៈ "...នាងខ្ញុំ បានឃើញផលិតផលសូត្រ និងកន្ទេលរបស់ខ្មែរយើង ...ដែលអាចយកទៅច្នៃជាផលិតផលប្រើប្រាស់ជាច្រើនប្រភេទ... នាងខ្ញុំក៏បែកគំនិត ក្នុងការបង្កើតអាជីវកម្មហ្នឹងឡើង ...ស្របពេលដែលខ្ញុំបង្កើតអាជីវកម្មហ្នឹង គឺគោលបំណងខ្ញុំមួយទៀត គឺជួយផ្តល់ ការងារ ជូនទៅដល់ ជនពិការ...ដែលភាគច្រើនជាស្ត្រី និងជនពិការ ...ដោយមិនប្រកាន់ពូជសាសន៍ ដោយសារថាមានស្ត្រីជនជាតិអ៊ីស្លាមក៏ចូលរួមដែរ... "។

សិប្បកម្មខ្មែរមួយនេះ បាននិងកំពុងទទួលបានជោគជ័យគួរឲ្យកត់សម្គាល់ ដោយហេតុថាបណ្តាផលិតផលរបស់សិប្បកម្ម ត្រូវបានអតិថិជនទទួលស្គាល់ថា មានគុណភាពខ្ពស់ និងថាត្រូវបានធ្វើឡើងដោយ គោរពតាមនិយាម ពាណិជ្ជកម្មដោយយុត្តិធម៌ (Fair Trade) ពោល គឺផ្តល់ប្រាក់កម្រៃ និងលក្ខខណ្ឌការងារសមស្របទៅដល់សិប្បករ សិប្បការិនី។ ជោគជ័យនេះ ត្រូវបានលោកស្រី បកស្រាយពន្យល់ថា មានមូលហេតុ សំខាន់ៗពីរយ៉ាងគឺការពិនិត្យគុណភាពជាប្រចាំ និង ការកម្រិតតម្លៃសមរម្យ ។

សិប្បកម្ម ខ្មែរ ខេ អិនអិន បាន និងកំពុងផ្តល់នូវ ឱកាសការងារជូនដល់ប្រជាពលរដ្ឋទីទ័លក្រ ចំនួន២៥ រូប ដែលជាង៨0ភាគរយគឺជាស្ត្រី ក្នុងនោះមាន១៤ រូប មកពីខេត្តដាច់ស្រយាល ចំនួន៧រូបមកពីតំបន់មានគ្រាប់មីន និងចំនួន២រូប គឺជាជនពិការ។

ទន្ទឹមនឹងជោគជ័យនេះ លោកស្រីក៏បានជួបប្រទះនឹងឧបសគ្គតិចតួចដែរ ពិសេសពាក់ព័ន្ធនឹងនីតិវិធីនាំចេញផលិតផលសិប្បកម្មរបស់លោកស្រី ។

ទាក់ទងនឹងដើមទុនបង្វិលវិញ សិប្បកម្មរបស់លោកស្រី ពុំជួបនិងការប្រឈមអ្វីទេ ដោយលោកស្រី បានប្រាប់ថា ៖ "...ពួកខ្ញុំមានរៀបចំជាដើមទុនបម្រុងមួយ... សម្រាប់ការងារហ្នឹង ដោយសារពួកខ្ញុំជាក្រុមហ៊ុន មិនមែនជាងខាងអង្គការទេ...គឺយើង ប្រើប្រាស់ដើមទុនក្រុមហ៊ុន ...អញ្ចឹងពួកខ្ញុំអត់មានបញ្ហាអ្វីទេ ..."។

ជារួម លោកស្រីបានសម្តែងមោទនភាពអំពីការបង្កើតសិប្បកម្មខ្មែរ មួយនេះ ដោយលោកស្រីបានមានប្រសាសន៍ថា ៖ "...ធ្វើឲ្យភ្ញៀវអន្តរជាតិ គាត់ទទួលស្គាល់អំពី ...សិប្បកម្មមួយនៃប្រទេសកម្ពុជា ដែលថា យើងបានផលិតប្រកបដោយគុណភាពខ្ពស់...។ នៅចុងបញ្ចប់នៃបទសម្ភាសន៍ លោកស្រី បានប្រាប់អំពីមហិច្ឆតារបស់លោកស្រីទៅអនាគតថាៈ "តាមពិត គោលបំណងរបស់ខ្ញុំ គឺថា ខ្ញុំចង់អិចស្ប៉ូស (បង្ហាញ) ខ្លួនឯងនៅលើឆាកអន្តរជាតិថា យើងពិតជាមានសមត្ថភាពផលិតបាន ផលិតផល ដែលមានគុណភាពល្អ ដែលអន្តរជាតិ គេទទួលស្គាល់..." ។ ជាអនុសាសន៍ សម្រាប់ស្ត្រី លោកស្រី មានប្រសាសន៍ថាៈ "ខ្ញុំគិតថា...ស្ត្រីយើង ឲ្យតែមានគោលបំណងមួយច្បាស់លាស់ជាមួយនឹងឆន្ទៈពិតប្រាកដរបស់យើង ថាយើងពិតជាអាចធ្វើការងារហ្នឹងបាន ការងារហ្នឹង យូរនិងឆាប់ប្រាកដជាអាចទទួលបានជោគជ័យ "៕

សម្រាប់ឯកសារនេះជាអេឡិចត្រូនិកៈ http://women.open.org.kh/km/women-economic-cambodia

## បណ្តាញ និង អង្គការស្ត្រី

### ស្ត្រីកម្ពុជាក្នុងអាជីវកម្ម

នាខែវិច្ឆិកា ឆ្នាំ២០០៩ កន្លងទៅ វេទិកាមួយត្រូវបានបង្កើតឡើងដោយ សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិតាមរយៈគេហទំព័របណ្តាញសង្គមមួយឈ្មោះថា ហ្វេសប៊ុក ( Facebook ) ក្រោមចំណងជើងថា " ស្ត្រីកម្ពុជាក្នុងអាជីវកម្ម " ក្នុងគោលបំណងដើរតួនាទី ជាកន្លែងសម្រាប់ចែករំលែកបទពិសោធន៍និងចំណេះដឹង ព្រមទាំងផ្តល់ព័ត៌មានស្តីពីការធ្វើអាជីវកម្មទៅដល់ក្រុមស្ត្រីខ្មែរ ដែលកំពុងធ្វើជំនួញ។

ដើម្បីស្វែងយល់ពីវេទិកានេះ ឲ្យបានច្បាស់ អង្គការវិទ្យាស្ថានបើកទូលាយ បានធ្វើបទសម្ភាសន៍មួយជាមួយលោកស្រី លីលី ស៊ីសម្បត្តិ ដែលជាប្រធានគម្រោងវេទិកា រវាងរាជរដ្ឋាភិបាលនិងផ្នែកឯកជននៃសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ និងជាអ្នកផ្តើមគំនិតបង្កើតវេទិកានេះឡើង។ បទសម្ភាសន៍នោះ មានខ្លឹមសារសង្ខេបដូចខាងក្រោម ៖

**សំណួរ ៖ តើមូលហេតុអ្វី បានជាវេទិកានេះត្រូវបានផ្តួចផ្តើមឡើង ?**

លោកស្រី លីលី ស៊ីសម្បត្តិ៖ មូលហេតុដែលនាងខ្ញុំ ផ្តើមគំនិតបង្កើតវេទិកានេះឡើងគឺថា កន្លងមកមានមិត្តភ័ក្តិទាំងខ្មែរនិងបរទេស បានបើករបរអាជីវកម្ម ដូចជាបើកហាងជាដើម នៅក្នុងប្រទេសកម្ពុជា។ នាងខ្ញុំបានមើលឃើញថា ពួកគេហាក់មានអារម្មណ៍ឯកោក្នុងការចាប់ផ្តើម ពោលគឺពុំដឹងថាទៅរកនរណាម្នាក់ឲ្យជួយដល់ខ្លួន នៅពេលដែលខ្លួនត្រូវការជំនួយ ដូចជាថាតើធ្វើយ៉ាងណាដើម្បីឲ្យអាចចូលក្នុងទីផ្សារបាន។ល។ នាងខ្ញុំ ក៏ខំរិះរកគំនិតថាតើធ្វើដូចម្តេចដើម្បីឲ្យអាចផ្សព្វផ្សាយពីការលំបាកនេះទៅដល់មនុស្សពីរពាន់នាក់ភ្លាមៗ ហើយអ្នកទាំងនោះអាចជួយដោះស្រាយ បញ្ហាលំបាកនេះបានភ្លាមៗដែរ។ ម្យ៉ាងទៀត នាងខ្ញុំចង់ស្វែងយល់ថាតើមានបញ្ហាអ្វីខ្លះដែលសហគ្រិនស្ត្រីបានប្រឈម បំណងលើកយកបញ្ហាប្រឈមទាំងនោះ ទៅក្នុងវេទិការវាងរាជរដ្ឋាភិបាល និងផ្នែកឯកជន។ នាងខ្ញុំក៏នឹកឃើញទៅដល់គេហទំព័រសង្គមមួយនៅលើប្រព័ន្ធអ៊ីនធឺណិត ដែលមានឈ្មោះថា ហ្វេសប៊ុក។ ដោយសារតែវាជាគេហទំព័រសង្គម យើងពុំតម្រូវឲ្យបង់ប្រាក់ឡើយ។ ជាងនេះទៀត គេអាចលើកយកបញ្ហា



សកម្មភាពក្នុងសិក្ខាសាលាសាស្តីអំពី" ស្ត្រីកម្ពុជាក្នុងអាជីវកម្ម"
រូបភាព៖ គេហទំព័រ ហ្វេសប៊ុក ស្ត្រីកម្ពុជាក្នុងអាជីវកម្ម

ផ្សេងៗមកពិភាក្សា ឬបញ្ចេញយោបល់ បានភ្លាមៗ ។ សរុបសេចក្តីមកវិញ នាងខ្ញុំបង្កើតវេទិកា "ស្ត្រីកម្ពុជាក្នុងអាជីវកម្ម" តាមប្រព័ន្ធអ៊ីនធឺណិតនេះ ក្នុងគោលបំណងពីរសំខាន់ ទីមួយ បង្កើតជាបណ្តាញសហគ្រិនស្ត្រី និងទីពីរ ស្វែងយល់ ពីបញ្ហាពាក់ព័ន្ធនឹងគោលនយោបាយរដ្ឋាភិបាល ដែលសហគ្រិនស្ត្រីបានប្រឈម។

**សំណួរ ៖ តើវេទិកានេះ បានទទួលជោគជ័យ និងសមិទ្ធិផលយ៉ាងដូចម្តេចខ្លះ ?**

លោកស្រី លីលី ស៊ីសម្បត្តិ៖ មកដល់ថ្ងៃនេះ វេទិកានេះមានសមាជិកចូលរួមចំនួន៥០០នាក់ ។ នាងខ្ញុំ ភ្ញាក់ផ្អើលលើតួរលេខនេះ ដោយសារតែពុំសូវមានសហគ្រិនស្ត្រីខ្មែរ ចូលរួម ហើយជាងនេះទៀតនោះគឺថា មានបុរសមួយចំនួនធំ ក៏បានចូលរួមដែរ។ ជាសមិទ្ធផលវិញ នាងខ្ញុំឃើញថា យើងទទួលបានព័ត៌មានដែលមានប្រយោជន៍ជាច្រើន សម្រាប់សហគ្រិនស្ត្រី ហើយបានធានាឲ្យមានកិច្ចពិភាក្សាគ្នាជាច្រើនដែលសុទ្ធសឹងតែល្អៗ។

**សំណួរ៖តើវេទិកានេះប្រឈមនឹងឧបសគ្គចម្បងៗអ្វីខ្លះ ?**

លោកស្រី លីលី ស៊ីសម្បត្តិ ៖ វេទិកាតាមរយៈហ្វេសប៊ុកនេះគ្រាន់តែជាការពិភាក្សាមួយ តាមប្រព័ន្ធអ៊ីនធឺណិត ឬក្រៅផ្លូវការតែប៉ុណ្ណោះ។ ដូច្នេះដើម្បីផ្សារភ្ជាប់ការពិភាក្សាតាមប្រព័ន្ធអ៊ីនធឺណិតនេះ ទៅនឹងការអនុវត្តន៍ជាក់ស្តែង យើងត្រូវប្រែក្លាយវេទិកានេះ ឲ្យទៅជាសមាគមធុរកិច្ចវិញ។ អ្វីដែលជាបញ្ហាចម្បងនោះគឺថាសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ ពុំអាចផ្តល់ការគាំទ្រជាអចិន្ត្រៃយ៍ទេ ពោលត្រូវមានក្រុមសហគ្រិនស្ត្រីណាមួយ មកគ្រប់គ្រងដំណើរការសមាគមធុរកិច្ចនេះ។ នាងខ្ញុំបារម្ភថា មិនដឹងថានៅពេលដែលប្រែក្លាយវេទិកានេះឲ្យទៅជាសមាគមធុរកិច្ចនោះ ថាតើវានឹងអាចដំណើរការទៅបានឆ្ងាយប៉ុណ្ណានោះឡើយ ព្រោះនេះទាមទារទាំងធនធានស្ត្រី និងទាំងធនធានហិរញ្ញវត្ថុ។

**សំណួរ ៖ តើមានផែនការយ៉ាងដូចម្តេចដើម្បីជំនះលើឧបសគ្គទាំងនេះ ?**

លោកស្រី លីលី ស៊ីសម្បត្តិ ៖ នេះជាសំណួរមួយ ពិបាកឆ្លើយ ។ នាងខ្ញុំគិតថា យើងគួរជ្រើសរើសស្ត្រីវ័យក្មេងៗ ដែលមានសក្តានុពលខ្ពស់ និងដែលមានចំណង់ចំណូលចិត្តចង់ធ្វើកិច្ចការខាងផ្នែកនេះ។ នាងខ្ញុំចង់ឲ្យបណ្តាស្ត្រីវ័យក្មេងៗ ដែលមានសក្តានុពលទាំងនោះ សហការគ្នាក្នុងការដំណើរការសមាគមបែបនេះ។

**សំណួរ ៖ តើក្រុមបណ្តាញនេះមានទំនាក់ទំនងជាមួយស្ថាប័នពាក់ព័ន្ធណាខ្លះ ?**

លោកស្រី លីលី ស៊ីសម្បត្តិ៖ សមាគមសហគ្រិនស្ត្រី ក៏ជាសមាជិកមួយក្នុងបណ្តាញរបស់យើងផងដែរ។ រាល់អនុសាសន៍ និងកិច្ចពិភាក្សាតាមហ្វេសប៊ុកត្រូវបានលើកយកមកពិភាក្សាក្នុងកិច្ចប្រជុំសហគ្រិននានា និងដាក់ទៅជូនដល់ក្រសួងកិច្ចការនារី។

**សំណួរ ៖ ជាចុងក្រោយ តើលោកស្រី មានសារអ្វីសម្រាប់សាធារណៈជន និងជាពិសេស ស្ត្រីក្នុងការប្រកបអាជីវកម្ម ?**

លោកស្រី លីលី ស៊ីសម្បត្តិ៖ នាងខ្ញុំសង្ឃឹមថា នឹងមានអ្នកចាប់អារម្មណ៍បង្កើតឲមាន សមាគមធុរកិច្ចមួយដែលអាចធ្វើឲបណ្តាញនេះ រឹតតែមានប្រសិទ្ធភាពនិងផ្សារភ្ជាប់ទៅនឹងការអនុវត្តន៍ជាក់ស្តែង ដែលអាចផ្តល់ប្រយោជន៍ដល់ស្ត្រីជាសហគ្រិន និងស្ត្រីទូទៅបានទូលាយ។

ព័ត៌មានបន្ថែម ទាក់ទងនឹងវេទិកា " ស្ត្រីកម្ពុជាក្នុងអាជីវកម្ម " នេះ អាចទទួលបានពីគេហទំព័រហ្វេសប៊ុក ដែលមានអាស័យដ្ឋាន www.facebook.com ដោយគ្រាន់តែវាយពាក្យ Cambodia Women in Business រួចចុចប៊ូតុង Search ។

សម្រាប់ឯកសារនេះជាអេឡិចត្រូនិក៖ http://women.open.org.kh/km/women-in-business-cambodia

## សង្គម និងការអភិវឌ្ឍន៍

(តពីទំព័រទី ១)

សេដ្ឋកិច្ចរបស់ស្ត្រីខ្មែរមានតែ៧០% ប៉ុណ្ណោះ គឺទាបជាងអត្រារបស់បុរសចំនួន១០% នេះបើយោងតាមលទ្ធផលនៃការស្ទាបស្ទង់ សង្គមសេដ្ឋកិច្ចខ្មែរ ហៅកាត់ថា CSES (Cambodian Socio-Economic Survey) ឆ្នាំ ២០០៧ របស់វិទ្យាស្ថានជាតិស្ថិតិ ។

ទោះជាយ៉ាងនេះក្ដី ក្រោមកិច្ចប្រឹងប្រែងជំរុញឲ្យមាន សមភាពយេនឌ័រ ពីសំណាក់រាជរដ្ឋាភិបាល និងអង្គការ សង្គមស៊ីវិល ស្ថានភាពស្ត្រីចូលរួមក្នុងសេដ្ឋកិច្ចមានការកើនឡើង។ ប្រភពពី អាយឡូ - ILO (២០០០) និង ពីវិទ្យាស្ថានជាតិស្ថិតិ (២០០៧) បានឲ្យដឹងថា ភាគរយស្ត្រីជាមេផ្ទះបានធ្លាក់ចុះ៧% ធៀបនឹងឆ្នាំ២០០០ មកត្រឹម ៥២% នៅ ឆ្នាំ២០០៧។ ទន្ទឹមនឹងនេះ ភាគរយស្ត្រី ជានិយោជក បានកើន៨% ធៀបនឹងឆ្នាំ ២០០០ ទៅដល់ ២០% ក្នុងឆ្នាំ ២០០៧។ បន្លាស់ប្ដូរបំណែងចែកស្ត្រីធ្វើការតាមអាជីពសំខាន់ៗ ទាំងនេះអាចឲ្យគេសន្និដ្ឋានបានថា វិសមភាពយេនឌ័រ ក្នុងសង្គមខ្មែរត្រូវបានកាត់បន្ថយ។



ពង្រឹងសម្ថភាពស្ត្រីដើម្បី បង្កើនវិស័យសេដ្ឋកិច្ចកម្ពុជា
រូបភាព៖ គេហទំព័រ ហ្វេសប៊ុក ស្ត្រីកម្ពុជាក្នុងអាជីវកម្ម

តែបើប្រៀបធៀបជាអន្តរជាតិវិញ ឃើញថា ភាពប្រសើរឡើងនៃកាលានុវត្តភាពស្ត្រីខ្មែរក្នុងសេដ្ឋកិច្ច នៅមានកម្រិត។ តាមសន្ទស្សន៍ ស្ដីពីកាលានុវត្តភាពស្ត្រីក្នុងសេដ្ឋកិច្ច ដោយ អង្គភាពស៊ើបអង្កេតសេដ្ឋកិច្ច (Economic Intelligence Unit) (EIU) ចេញផ្សាយខែមិថុនា ឆ្នាំ២០១០ នេះបានឲ្យដឹងថា កម្ពុជាទទួលបានចំណាត់ថ្នាក់ទី៩២ ក្នុងចំណោមប្រទេសចំនួន១១៣ និងទទួលបានពិន្ទុចំនួន៣៩,២ លើពិន្ទុ១០០។ ពោលគឺ កាលានុវត្តនភាពក្នុងសេដ្ឋកិច្ចរបស់ស្ត្រីខ្មែរ មានភាពប្រសើរជាងស្ត្រីឡាវ ដោយប្រទេសឡាវ ទទួលបានចំណាត់ថ្នាក់ទី១០០។ ក៏ប៉ុន្តែ បើប្រៀបធៀបនឹងស្ត្រីថៃ និងវៀតណាមវិញ គេបានឃើញថា កាលានុវត្តភាពស្ត្រីក្នុងសេដ្ឋកិច្ចរបស់ស្ត្រីខ្មែរ មានភាពអន់ថយខ្លាំងណាស់ដោយប្រទេសទាំងពីរនោះ ទទួលបានចំណាត់លេខរៀង គ្នា ទី ៤៨ និង ៧៩ គឺខ្ពស់ជាច់ឆ្ងាយជាងប្រទេសកម្ពុជា ។

សន្ទស្សន៍ស្ដីពីកាលានុវត្តភាពស្ត្រីក្នុងសេដ្ឋកិច្ចនៃអង្គភាពស៊ើបអង្កេតសេដ្ឋកិច្ច (EIU) នេះ ផ្អែកលើសូចនាករសំខាន់ៗ ចំនួន ៥ ៖ (១) គោលនយោបាយការងារ និង ការអនុវត្ត (២) លទ្ធភាពទទួលបានប្រាក់ កម្ចី (៣)ការអប់រំ និងការបណ្ដុះបណ្ដាល (៤)ឋានៈស្ត្រីទាំងក្នុងផ្លូវច្បាប់ និងក្នុងសង្គម និង (៥)បរិយាកាសធុរកិច្ចទូទៅ ។

ចំពោះសូចនាករទី ២ ដែល ទាក់ទងទៅនឹង លទ្ធភាពទទួលបានប្រាក់កម្ចី អង្គភាពស៊ើបអង្កេតសេដ្ឋកិច្ច ដដែលខាងលើបានបង្ហាញថា ប្រទេសកម្ពុជាទទួលបានពិន្ទុតែ៦,៣ លើពិន្ទុ ១០០ ប៉ុណ្ណោះ ។ នេះ មានន័យថាលទ្ធភាពដែលស្ត្រីខ្មែរអាចទទួលបាន ប្រាក់កម្ចី គឺ នៅមានកម្រិតទាបខ្លាំង ។

លោកស្រី លីលី ស៊ី សម្បត្តិ ប្រធានគម្រោងវេទិការវាងរាជរដ្ឋាភិបាល និងផ្នែកឯកជននៃសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ និងជាអ្នកផ្ដើមគំនិតបង្កើតវេទិកា "ស្ត្រី កម្ពុជា ក្នុង អាជីវកម្ម" បានសម្ដែងការមិនយល់ស្របចំពោះការផ្ដល់ពិន្ទុដល់ ប្រទេសកម្ពុជាទាក់ទងនឹងសូចនាករទី២ នេះ ដោយបានផ្ដល់ទឡ្ហីករថា បើតាមការសង្កេតរបស់លោកស្រី ស្ត្រីខ្មែរហាក់ពុំមានការលំបាកក្នុងការទទួលបានប្រាក់កម្ចីឡើយ។ លោកស្រីបានលើកឡើងទៀតថា ភាគច្រើននៃអតិថិជនរបស់ធនាគារ អេ.ស៊ី. លី.ដា និងបណ្ដាស្ថាប័នមីក្រូហិរញ្ញវត្ថុនានា គឺជាស្ត្រីភេទ។ លោកស្រីបន្តថា អ្វីដែលជាឧបសគ្គសម្រាប់ស្ត្រីក្នុងការចូលរួម



ទិដ្ឋភាពសិក្ខាសាលា ស្ត្រីកម្ពុជាក្នុងអាជីវកម្ម
រូបភាព៖ គេហទំព័រ ហ្វេសប៊ុក ស្ត្រីកម្ពុជាក្នុងអាជីវកម្ម

សកម្មភាពសេដ្ឋកិច្ចនោះ គឺ កង្វះលទ្ធភាពទទួលបានការអប់រំ។

លទ្ធផលពី ការស្ទាបស្ទង់ សង្គមសេដ្ឋកិច្ច (CSES) របស់ វិទ្យាស្ថានជាតិ ស្ថិតិ បានបញ្ជាក់ឲ្យឃើញថាភាគរយនៃស្ត្រី ដែលគ្មានឬទទួលបានការអប់រំខ្លះចូលរួមក្នុងសកម្មភាពសេដ្ឋកិច្ច មានកម្រិតរហូតដល់ទៅ ២៥% គឺ ខ្ពស់ជាងបុរស ចំនួន១៤%។ ផ្ទុយទៅវិញ ភាគរយនៃស្ត្រីដែល បានបញ្ចប់មធ្យមសិក្សាឬខ្ពស់ជាងនេះហើយ ចូលរួមក្នុងសកម្ម ភាពសេដ្ឋកិច្ច មានតែ ១២% ប៉ុណ្ណោះ គឺទាបជាងភាគរយរបស់បុរសចំនួន៨% ។

តួលេខទាំងនេះអាចឲ្យគេធ្វើការសន្និដ្ឋានបានថា កាលានុវត្តភាពស្ត្រី ក្នុងសេដ្ឋកិច្ច នៅសង្គមខ្មែរបច្ចុប្បន្នមានកម្រិតខ្ពស់ ចំពោះវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ ឬ វិស័យដែលតម្រូវឲ្យមានជំនាញវិជ្ជាជីវៈតិចតួច។ ចំពោះវិស័យសេដ្ឋកិច្ចក្នុងប្រព័ន្ធវិញ ឬ វិស័យ ដែល ទាមទារនូវជំនាញវិជ្ជាជីវៈខ្ពស់ កាលានុវត្តភាពស្ត្រីខ្មែរ ក្នុង សេដ្ឋកិច្ច នៅមានកម្រិតស្ដួចស្ដើងនៅឡើយ ។

ផ្អែកលើបរិបទដូចបានពិភាក្សាមកខាងលើ អ្វីដែលជាកិច្ចសំខាន់បំផុតនោះ គឺការជំរុញសមភាព យេនឌ័រ ខាងផ្នែក អប់រំ ដែលជាកតាលិករដ៏មានប្រសិទ្ធភាព សម្រាប់ការអភិវឌ្ឍប្រកបដោយចិរភាព និងដោយសមភាពក្នុងសង្គមទៅអនាគត៕

សម្រាប់ឯកសារនេះជាអេឡិចត្រូនិក៖
http://women.open.org.kh/km/women-opportunity-economic

## វិធីសាស្ត្រគ្រប់គ្រងមុខជំនួញ

### វិធីសាស្ត្រគ្រប់គ្រងមុខជំនួញធុនតូចឲ្យបានជោគជ័យ




សៀវភៅអាថ៌កំបាំងក្នុងការគ្រប់គ្រងមុខជំនួញធុនតូច
រូបភាព៖ អង្គការវិទ្យាស្ថានបើកទូលាយ

កិច្ចការសំខាន់បំផុតរបស់សហគ្រាសទូទៅ គឺការបង្កើនប្រាក់ចំណូល។ ប៉ុន្តែ ដើម្បីសម្រេចកិច្ចការនេះឲ្យបានជោគជ័យ សហគ្រិនចាំបាច់ត្រូវមានសមត្ថភាពគ្រប់គ្រងអាជីវកម្មខ្លួនឲ្យបានល្អប្រសើរ។ ដូចនេះ តើសហគ្រិនត្រូវមានយុទ្ធសាស្ត្រយ៉ាងណាដើម្បីគ្រប់គ្រងអាជីវកម្មខ្លួន?

សៀវភៅជាភាសាអង់គ្លេសមួយដែលមានចំណងជើងថា "Secrets for Running a Small Business " ឬប្រែជាភាសាខ្មែរថា "អាថ៌កំបាំងក្នុងការគ្រប់គ្រងមុខជំនួញធុនតូច" របស់លោក តូស៊ុ ហ្វិកាមី ដែលជាអ្នកនិពន្ធជនជាតិជប៉ុនមួយរូប ពិតជាអាចផ្តល់ចម្លើយចំពោះសំណួរខាងលើនេះបាន ពីព្រោះសៀវភៅនេះបានពន្យល់យ៉ាងក្បោះក្បាយ ទាំងតាមបែបជាទ្រឹស្តីនិងការអនុវត្តជាក់ស្តែងអំពីវិធីសាស្ត្រដើម្បីធ្វើអាជីវកម្មសហគ្រាសធុនតូចនិងមធ្យមឲ្យប្រកបដោយទេពកោសល្យខ្ពស់។

អ្នកនិពន្ធជនជាតិជប៉ុនរូបនេះបានបកស្រាយ រួមមានគោលការណ៍ប្រាំចំណុចសំខាន់ៗ។ ទី១ ការគ្រប់គ្រងទីផ្សារគឺជាចំណុចគន្លឹះសម្រាប់ញ៉ាំងឲ្យពាណិជ្ជករ អាចបង្កើនការលក់ដូរផលិតផល ក៏ដូចជាប្រាក់ចំណេញរបស់ខ្លួនបានជាទីគាប់ប្រសើរ។

ទី២ ការគ្រប់គ្រងហិរញ្ញវត្ថុគឺមិនមែនគ្រាន់តែជាការគិតគូរអំពីលម្ហូរសាច់ប្រាក់ ឬដើមទុនប៉ុណ្ណោះទេ តែទាក់ទងនឹងការវិភាគឲ្យបានវែងឆ្ងាយនិងការពិនិត្យពិច័យនានារាប់ចាប់តាំងពីលើរបាយការណ៍ចំណេញខាត លើសមតុល្យ រហូតដល់លើការចាប់ផ្តើមគ្រប់គ្រងហិរញ្ញវត្ថុ ដែលមានលម្អិតពីទំហំទ្រព្យសម្បត្តិដែលអាចប្តូរជាសាច់ប្រាក់និងដើមទុនបានភ្លាមៗ សម្រាប់យកប្រើប្រាស់ក្នុងពេលមានអាសន្នជាដើម។

ទី៣ ការគ្រប់គ្រងពលកម្ម គឺទាមទារនូវស្មារតីលះបង់និងភាពអត់ធ្មត់ខ្លាំង។ ជាទូទៅកម្មករអាចនឹងមិនធ្វើការឲ្យបានសម្រេចមួយរយភាគរយដូចដែលម្ចាស់ក្រុមហ៊ុនចង់បាននោះទេ។ ដូច្នេះ សមាជិកម្នាក់ៗ ចាំបាច់ត្រូវបំពេញលើចន្លោះខ្វះខាតរបស់សហសេវិកខ្លួន ហើយតម្រូវឲ្យមាននូវការអធ្យាស្រ័យ និងការគោរពវិន័យច្បាស់លាស់។ ប្រសិនបើកម្មករមិនត្រូវបានគេយកចិត្តទុកដាក់និងផ្តល់ផលប្រយោជន៍ទេនោះ ពួកគេហាក់ដូចជាមិនយកចិត្តទុកដាក់ក្នុងការងារទេ ។ ដោយសារកត្តានេះហើយ សហគ្រិនត្រូវផ្តល់ជាការសរសើរដល់កម្មករទាំងនោះ ប៉ុន្តែក៏មិនត្រូវភ្លេចពីកម្មវត្ថុនៃការចង់បង្កើនការលក់ដូរ និងផលកម្រៃនោះឡើយ។

ទី៤ ការផ្គត់ផ្គង់ទុន ពោលគឺសំដៅទៅលើការរកស៊ីជាមួយធនាគារ ក្នុងករណីដែលខ្វះដើមទុនឬត្រូវការដើមទុនបន្ថែមសម្រាប់ពង្រីកមុខរបរ។ ដើម្បីសម្រេចគោលការណ៍ទី៤នេះ អ្នកនិពន្ធបានផ្តល់ជាយោបល់ទាក់ទងនឹងកិច្ចការសំខាន់ៗចំនួនពីរបន្ថែមទៀត។ កិច្ចការទី១ គឺថាសហគ្រិនត្រូវតែបង្ហាញថាខ្លួនពិតជាមានគម្រោងអាជីវកម្មមួយដែលអាចផ្តល់នូវផលចំណេញខ្ពស់ តាមរយៈ ការដាក់របាយការណ៍ហិរញ្ញវត្ថុរបស់គម្រោងអាជីវកម្មនោះ ទៅដល់ធនាគារដែលខ្លួនចង់សហការជាមួយ។ កិច្ចការទី២វិញ គេចាំបាច់ត្រូវគោរពឲ្យបាននូវភាពទៀងទាត់ចំពោះរាល់ប្រតិបត្តិការអាជីវកម្មនានាជាមួយធនាគារ ។ នេះមានន័យថា គេត្រូវទូទាត់សងលុយឲ្យបានទាន់ពេលនិងទៀងតាមកាលកំណត់ ដែលករណីនេះនឹងជួយសាងប្រវត្តិល្អដល់អ្នកខ្ចី ហើយជាលទ្ធផលនឹងទទួលបានការជឿទុកចិត្តពីធនាគារដែលនឹងនាំឲ្យងាយស្រួលទទួលបានប្រាក់កម្ចីលើកក្រោយៗទៀត បើទោះបីជាមិនមានវត្ថុធានាក្តី ។

ទី៥ ដែលជាគោលការណ៍ចុងក្រោយនោះ គឺគោលនយោបាយពន្ធដារ ពោលសំដៅដល់ការគិតគូរ ឬការដោះស្រាយ ថាតើចំនួនពន្ធប៉ុន្មានដែលត្រូវបង់ ហើយត្រូវបង់យ៉ាងដូចម្តេចដើម្បីឲ្យបានត្រឹមត្រូវ។ ទង្វើនេះនឹងផ្តល់ជាគន្លឹះក្នុងការបែកជាគំនិតច្នៃប្រឌិតពង្រីក រឺបង្កើនអាជីវកម្មរបស់ខ្លួនបានដោយអាចកាត់បន្ថយ នូវការបង់ពន្ធដោយស្របច្បាប់។

សរុបសេចក្តីមក ការអនុវត្តតាមគោលការណ៍ប្រាំយ៉ាងដូចបានរៀបរាប់ក្នុងសៀវភៅនេះ នឹងអាចផ្តល់ជាយុទ្ធសាស្ត្រដល់សហគ្រិនទាំងឡាយ ដើម្បីគ្រប់គ្រងអាជីវកម្មរបស់ខ្លួនប្រកបដោយជោគជ័យនិងកិត្តិស័ព្ទជាអ្នកគ្រប់គ្រងដ៏ល្អ ។

សម្រាប់ឯកសារនេះជាអេឡិចត្រូនិក៖ http://women.open.org.kh/km/secrets-running-small-business

## ចំណុចគន្លឹះក្នុងការប្រើប្រាស់បច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា

### តើអ្វីទៅជាកម្មវិធីការិយាល័យខ្មែរ ?

កម្មវិធីការិយាល័យខ្មែរ (OpenOffice.org) គឺជាកម្មវិធីកុំព្យូទ័រមួយប្រភេទដែលអាចប្រើសម្រាប់ការងារការិយាល័យ ដូចជា សរសេរអត្ថបទ គ្រប់គ្រងសៀវភៅបញ្ជី ឬទិន្នន័យលេខ ធ្វើបទបង្ហាញ គូររូបសាមញ្ញៗ ជាដើម ។

កម្មវិធីការិយាល័យមានគុណសម្បត្តិជាច្រើនដូចជា ៖

- គ្មានការបង់ថ្លៃលើអាជ្ញាប័ណ្ណ ៖ អ្នកប្រើទាំងអស់មានសិទ្ធិប្រើប្រាស់ និងចែកចាយដោយសេរី ។
- កូដចំហ ៖ អ្នកអាចចែកចាយ ចម្លង និងកែសម្រួលកម្មវិធីនេះដោយសេរី ។
- ប្រើបានច្រើនប្រព័ន្ធ (Cross Platform) ៖ កម្មវិធីនេះ អាចដំណើរការលើស្ថាបត្យកម្មផ្នែករឹងជាច្រើន និងប្រព័ន្ធប្រតិបត្តិការចម្រុះដូចជា ម៉ៃក្រូសូហ្វវីនដូ (Microsoft Windows), Mac OS X, Linux និង Sun Solaris ។

(តទៅទំព័រទី ៨)

( តពីទំព័រទី ៧ )

- មានច្រើនភាសា ( ជាង ៤០ ភាសា ) ៖ វាមានចំណុចប្រទាក់អ្នកប្រើ ( User Interface ) ដែលអាចធ្វើការផ្លាស់ប្តូរបានច្រើនភាសា ។ ពិសេសចំណុចប្រទាក់ជាភាសាខ្មែរ ដែលធ្វើឲ្យអ្នកងាយស្រួលប្រើ ចងចាំបានយូរ សន្សំសំចៃពេលវេលា និងថវិកាក្នុងការរៀន និងប្រើប្រាស់វា ។
- មានបញ្ចូលនូវកម្មវិធីពិនិត្យអក្ខរាវិរុទ្ធនៃការសរសេរពាក្យខ្មែរ ដែលអាចជួយអ្នកមិនឲ្យសរសេរពាក្យខុសច្រើន ។
- អាចតម្រៀបអក្សរខ្មែរតាមលំដាប់អក្ខរក្រម ។

## សមាសធាតុនៃកម្មវិធីការិយាល័យខ្មែរ

នៅក្នុងកម្មវិធីការិយាល័យ រួមមានសមាសភាគ ( កម្មវិធី ) ជាច្រើនដូចជា ៖

- កម្មវិធីស្លឹករឹត ( OpenOffice.org Writer )

ស្លឹករឹត ( Writer ) គឺជាកម្មវិធីមួយសម្រាប់សរសេរ និងរៀបចំអត្ថបទ បង្កើតសំបុត្រ សៀវភៅ ធ្វើរបាយការណ៍ សារព័ត៌មាន ប័ណ្ណផ្សាយពាណិជ្ជកម្មជាដើម ។ ស្លឹករឹត អាចនាំចេញឯកសារជាទ្រង់ទ្រាយផ្សេងៗដូចជា HTML, XHTML, PDF និង Microsoft Word ។ល ។



- កម្មវិធីនព្វន្ត ( OpenOffice.org Calc )

នព្វន្ត ( Calc ) គឺជាកម្មវិធីសៀវភៅបញ្ជីមួយដែលមានជំនាញទាក់ទងនឹងការគណនា បង្កើតតារាង និងមានលក្ខណៈសម្បត្តិខាងវិភាគទិន្នន័យ បង្កើតគំនូសតាងឲ្យទិន្នន័យ ធ្វើការគណនារូបមន្តជាច្រើនសម្រាប់ការងារហិរញ្ញវត្ថុ ស្ថិតិ គណិតវិទ្យាជាដើម ។ល ។



- កម្មវិធីពិព័រណ៍ ( OpenOffice.org Impress )

ពិព័រណ៍ ( Impress ) ជាកម្មវិធីមួយដែលអាចឲ្យអ្នករចនាស្លាយសម្រាប់ធ្វើការបង្ហាញផ្សេងៗ។ ជាមួយកម្មវិធីពិព័រណ៍ អ្នកអាចដាក់ចលនាឲ្យវត្ថុ ដាក់សំឡេង កំណត់ដំណើរផ្លាស់ប្តូរស្លាយ និងកំណត់ការបញ្ចាំងស្លាយជាដើម ។




( មានតទៅលេខក្រោយ )

## កម្មវិធីនៃអង្គការសន្តិភាព និងអភិវឌ្ឍន៍ ( PyD )

អង្គការសន្តិភាព និងអភិវឌ្ឍន៍ គឺជាអង្គការអន្តរជាតិក្រៅរដ្ឋាភិបាលមួយរបស់ ប្រទេសអេស្ប៉ាញ ដែលមានកម្មវិធីរយៈពេលបួនឆ្នាំ ឈ្មោះថា " ការបង្កើនឱកាស និងលើកកម្ពស់ស្ត្រីកម្ពុជាក្នុងការរួមចំណែកនៅក្នុងវិស័យសង្គម សេដ្ឋកិច្ច និងនយោបាយ " នៅតំបន់ភូមិភាគឦសាន្ត រួមមានខេត្តក្រចេះ ស្ទឹងត្រែង រតនគិរី និងមណ្ឌលគិរី។ បច្ចុប្បន្នអង្គការសន្តិភាព និងអភិវឌ្ឍន៍បាននិងកំពុងអនុវត្តគម្រោង ចំនួនបីគឺ៖

( ១ ) គម្រោងយេនឌ័រ និងសិទ្ធិស្ត្រី

( ២ ) គម្រោងអភិវឌ្ឍន៍សង្គម និងសេដ្ឋកិច្ច

( ៣ ) គម្រោងសិទ្ធិផ្នែកផ្លូវភេទ និងសុខភាពបន្តពូជ


ទំនាក់ទំនងព័ត៌មាន៖

ការិយាល័យភ្នំពេញ

ទូរស័ព្ទលេខ៖ ០២៣ ៩៩៤ ៧៤១/

០២៣ ៩៨៧ ៨៤១

ទូរសារលេខ៖ ០២៣ ៩៨៧ ៨៤១

ការិយាល័យស្ទឹងត្រែង

ទូរស័ព្ទលេខ៖ ០៧៤ ៩៧៣ ៦៣៣



រៀបចំ និងបោះពុម្ពផ្សាយដោយ ៖

វិទ្យាស្ថានបើកទូលាយ Open Institute

ផ្ទះលេខ ១៩ ផ្លូវ៣៧៤ ( ទល់មុខសាលាសង្កាត់ទួលស្វាយព្រៃទី១ )

ទូរស័ព្ទលេខ ៖ ( ៨៥៥-២៣ ) ២២៤ ៨២១

Website: http://open.org.kh; Email: women@open.org.kh

ឧបត្ថម្ភដោយ ៖

MINISTERIO DE ASUNTOS EXTERIORES Y DE COOPERACIÓN

aecid